

# រាល់ថ្ងៃនីមួយៗគឺមានតម្លៃណាស់

## ចូលរៀនថ្ងៃនេះ –
## សំរេចបានជោគជ័យថ្ងៃស្អែក!

**ការមករៀនទៀងទាត់រាល់ថ្ងៃ គឺសំខាន់ណាស់នៅក្នុងថ្នាក់មតេយ្យ និងថ្នាក់ទីមួយ ពីព្រោះ :**

- កុមារទាំងឡាយរៀនអាន និងសរសេរក្នុងថ្នាក់មតេយ្យ និងថ្នាក់ទីមួយ
- កំរិតថ្នាក់ទាំងនេះផ្តល់អោយនូវមូលដ្ឋានក្នុងការយល់គណិតសាស្ត្រ
- កុមារទាំងឡាយរៀនពីរបៀបធ្វើជាកូនសិស្សល្អនៅដើមឆ្នាំ
- កូនសិស្សទាំងឡាយចេះលេងកំសាន្ត និងរកបានមិត្តភ័ក្តច្រើននៅពេលគេមកសាលារៀន

**សំណួរនានាអំពីការមករៀនទៀងទាត់នៃកូនលោកអ្នក នឹងត្រូវបានឆ្លើយតប :**

**ជួបនិយាយជាមួយគ្រូបង្រៀនរបស់កូនលោកអ្នក បើសិនជា :**

ក) លោកអ្នកគិតថាគេគួសច្រឡំថា កូនលោកអ្នកខានមករៀន ឬមករៀនយឺតម៉ោង
ខ) កូនលោកអ្នកពុំចង់មកសាលារៀន ដោយសារតែគេមានបញ្ហាផ្នែកសង្គម ឬផ្នែកការសិក្សាមុខវិជ្ជាសិក្សា
គ) លោកអ្នកមានការសំខាន់ក្នុងគ្រួសារ ដែលធ្វើអោយកូនលោកអ្នកខានមករៀន ហើយលោកអ្នកចង់ដឹងពីរបៀបអោយកូនធ្វើកិច្ចការអោយគ្រប់ចំនួនជូនគ្រូវិញ

**ជួបនិយាយជាមួយនឹងបុគ្គលិកនៃការិយាល័យខាងមុខ បើសិនជា :**

ក) លោកអ្នកត្រូវការដកចេញនូវថ្ងៃខានមករៀនពីបញ្ជី ឬរាយការណ៍ប្រាប់ពីថ្ងៃខានមករៀន
ខ) កូនលោកអ្នកត្រូវតែខានមករៀនដើម្បីទៅពេទ្យ ឬក៏គ្រុនខ្លាំងពេក មករៀនមិនកើត។ សូមកុំភ្លេច យកសំបុត្រមួយច្បាប់មកពីពេទ្យ មកអោយសាលារៀន។

**ជួបនិយាយជាមួយចាងហ្វាងសាលារៀន បើសិនជា :**

លោកអ្នកចង់ដឹងថាតើកូនលោកអ្នកអាចមានផលប៉ះពាល់យ៉ាងណាដែរចំពោះការខានមករៀនច្រើនថ្ងៃ។

**បើសិនជាគ្រួសាររបស់លោកអ្នកជួបនឹងបញ្ហាពិបាកៗ សង្កាត់សាលារៀនអូកឡិនដ៍អាចជួយ!**

ក) បញ្ហាសុខភាព : សូមទូរស័ព្ទមកកាន់ទីបំរើសេវាសុខភាព ឬអ្នកគ្រូពេទ្យប្រចាំសាលារៀនរបស់កូនលោកអ្នកនៅលេខ 510-879-8816
ខ) ពុំមានទីកន្លែងរស់នៅ : សូមទូរស័ព្ទទៅកាន់ផ្នែកកូនសិស្ស និងគ្រួសារអន្តរកាល តាមរយៈទូរស័ព្ទលេខ 510-434-7776
គ) ពុំមានឡាន : សូមទូរស័ព្ទទៅកាន់ការិយាល័យចុះឈ្មោះរៀនតាមរយៈទូរស័ព្ទ លេខ 510-434-7752 លេខបន្ថែម 224



# ជួយកូនលោកអ្នកទទួលបានជោគជ័យក្នុងសាលារៀន :

បង្កើតទម្លាប់ល្អក្នុងការមករៀនទាន់ពួកគេនៅតូចៗ
ជោគជ័យក្នុងការសិក្សា គឺមកពីការមករៀនបានទៀងទាត់រាល់ថ្ងៃ!

## លោកអ្នកដឹងទេ?

- ចាប់ពីថ្នាក់មតេយ្យ ការខានមករៀនច្រើនដង អាចធ្វើអោយកុមាររៀនពុំទាន់គេ។
- ការខានមករៀន 10 ភាគរយ (ឬប្រហែលជា 18 ថ្ងៃ) អាចធ្វើអោយមានការពិបាករៀនអាន។
- កូនសិស្សអាចនៅតែរៀនមិនទាន់គេ បើគេគ្រាន់តែខានមកមួយថ្ងៃ ឬពីរថ្ងៃ ជារៀងរាល់ពីបីសប្តាហ៍ម្តង។
- ការមករៀនយឺតម៉ោង អាចបណ្តាលអោយមានការខានមករៀនច្រើនដង។
- ការខានមករៀនអាចប៉ះពាល់ថ្នាក់រៀនទាំងមូល បើសិនជាគ្រូបង្រៀនត្រូវពន្យឺតការរៀនសូត្រ ដើម្បីជួយកុមារទាំងឡាយអោយរៀនបានទាន់គ្នា។

ការមករៀនទៀងទាត់រាល់ថ្ងៃ ជួយអោយកុមារមានអារម្មណ៍ល្អទៅលើសាលារៀន – និងលើខ្លួនពួកគេ។ សូមចាប់ផ្តើមបង្កើតទម្លាប់ល្អនេះ ទាន់នៅរៀនសាលាព្រីស្គូល ដើម្បីអោយពួកគេអាចរៀនសូត្រភ្លាមៗ ថា ការទៅរៀនបានទាន់ម៉ោង និងការទៅរៀនទៀងទាត់រាល់ថ្ងៃ គឺសំខាន់ណាស់។ ការមករៀនទៀងទាត់រាល់ថ្ងៃ នឹងជួយអោយកុមាររៀនបានពូកែក្នុងសាលាហៃស្កូល មហាវិទ្យាល័យ និងក្នុងវិស័យការងារ។

## តើលោកអ្នកអាចធ្វើអ្វីខ្លះ

- ដាក់ម៉ោងចូលគេងពីព្រលប់ និងក្រោកពីព្រលឹមអោយបានទៀងទាត់រាល់ថ្ងៃ។
- រៀបចំទុកខោអាវ និងកាបូបសៀវភៅ ពីល្ងាចអោយហើយ
- ដឹងពីថ្ងៃចូលរៀនដំបូង និងធ្វើយ៉ាងណាអោយកូនលោកអ្នកបានទៅចាក់ថ្នាំបង្ការរោគបានគ្រប់ចំនួន។
- ណែនាំកូនលោកអ្នកអោយស្គាល់គ្រូបង្រៀន និងមិត្តរួមថ្នាក់របស់ពួកគេ មុនសាលារៀនចាប់ផ្តើម ដើម្បីជួយអោយពួកគេស៊ាំនឹងការផ្លាស់ប្តូររបស់ពួកគេ។
- កុំអនុញ្ញាតអោយកូនលោកអ្នកនៅផ្ទះ បើសិនជាគេមិនគ្រុនទេនោះ។ សូមចាំទុកក្នុងចិត្តថា ការពោលថា ឈឺពោះ ឬក្បាលនោះ អាចជាសញ្ញាភ័យបារម្ភ ហើយពុំមែនជាមូលហេតុអោយស្នាក់នៅផ្ទះទេ។
- បើសិនជាកូនលោកអ្នកហាក់បីដូចជាភ័យបារម្ភអំពីការទៅរៀន សូមជួបនិយាយជាមួយគ្រូបង្រៀន ខុនសិល្លើសាលារៀន ឬមាតាបិតាផ្សេងទៀត ដើម្បីសួរយោបល់អំពីរបៀបធ្វើអោយពួកគេស្រួលក្នុងចិត្ត ហើយចង់ទៅរៀន។
- បង្កើតផែនការបម្រុងទុកសំរាប់ទៅរៀន  បើសិនជាមានរឿង។ សូមទូរស័ព្ទរកសមាជិកគ្រួសារ អ្នកជិតខាង ឬរកមាតាបិតាផ្សេងទៀត។
- បញ្ចៀសការណាត់ជួបពេទ្យ និងការធ្វើដំណើរកំសាន្តថែមទៀត នៅពេលណាសាលារៀនកំពុងចាប់ផ្តើមបើកបង្រៀន។

## តើនៅពេលណាការខានមករៀន ក្លាយទៅជាបញ្ហា?



**ការខានមករៀនឥតស្រាកស្រាន**
18 ថ្ងៃ ឬច្រើនជាងនេះ



**សញ្ញាប្រាប់អោយជាមុន**
ពី 10 ដល់ 17 ថ្ងៃ



**ការមករៀនទៀងទាត់ល្អ**
ការខានមករៀន 9 ថ្ងៃ ឬតិចជាងនេះ

កំណត់សំគាល់ : តួរលេខទាំងនេះសន្មត់លើឆ្នាំសិក្សាចំនួន 180 ថ្ងៃ។

សំរាប់ពត៌មានបន្ថែមអំពីការត្រៀមខ្លួនចូលរៀន សូមចុចមើលក្នុងគេហទំព័រ attendanceworks.org និង reachoutandread.org។